**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តកណ្តាល**

លេខៈ៧២៦./២៦ សជណ

ថ្ងៃចន្ទ..១២..កើត..ខែ..ចេត្រ....ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៦៩

ខេត្តកណ្តាល ថ្ងៃទី៣០...ខែមីនា..ឆ្នាំ២០២៦

# សេចក្តីជូនដំណឹងលើកទី២

## ស្តីពី

## ការហាមឃាត់ ការទប់ស្កាត់ការសាងសង់សំណង់ ការលក់ដូរ ការធ្វើអាជីវកម្ម ការដាក់ផ្ទាំងប៉ាណូ និងស្លាកផ្សាយពាណិជ្ជកម្មគ្មានច្បាប់អនុញ្ញាត និងការរុករើសំណង់ នៅលើដីចំណីផ្លូវសាធារណៈ ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តកណ្តាល

**យោង** ÷- ព្រះរាជក្រមលេខ នស/រកម/០៥១៤/០០៨ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៤ ប្រកាសឱ្យប្រើច្បាប់ស្តីពីផ្លូវថ្នល់

- អនុក្រឹត្យលេខ ១៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងដីចំណីតាមបណ្តាញផ្លូវជាតិ និងផ្លូវរថភ្លើង នៃព្រះរាជាណាចក្រកម្ពុជា
- លិខិតលេខ ០០៧ សរ.សក ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៦ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន ស្តីពីវិធានការពង្រឹងការគ្រប់គ្រង និងការប្រើប្រាស់ដីចំណីផ្លូវ (ផ្លូវជាតិ ផ្លូវខេត្ត)
- សេចក្តីណែនាំរួមរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន និងសាលាខេត្តកណ្តាល ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងដីចំណីផ្លូវ
- លិខិតលេខ ៦០០/២៦ សជណ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៦ របស់ រដ្ឋបាលខេត្តកណ្តាល។

**រដ្ឋបាលខេត្តកណ្តាល** មានកិត្តិយសសូមជម្រាបជូន សាធារណជន បងប្អូនអាជីវករ និងបងប្អូនប្រជាពលរដ្ឋក្នុងខេត្តកណ្តាល មេត្តាជ្រាបថា បន្ទាប់ពីការជូនដំណឹងលើកទី១ រដ្ឋបាលខេត្ត សង្កេតឃើញថា នៅតាមបណ្តោយផ្លូវជាតិ ផ្លូវខេត្ត និងតាមដងផ្លូវផ្សេងៗទៀត ជាពិសេសតំបន់ទីប្រជុំជន ក្នុងភូមិសាស្ត្រខេត្តកណ្តាល នៅតែមានការសាងសង់សំណង់រឹង ការលក់ដូរ ការធ្វើអាជីវកម្ម ការដាក់ផ្ទាំងប៉ាណូ និងស្លាកផ្សាយពាណិជ្ជកម្ម គ្មានច្បាប់អនុញ្ញាត រំលោភលើដីចំណីផ្លូវសាធារណៈ ដែលនាំឱ្យបាត់បង់នូវសោភណភាព សន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ របៀបរៀបរយនៅតាមដងផ្លូវ រារាំងដល់គម្រោងពង្រីកផ្លូវ ឬគម្រោងអភិវឌ្ឍន៍ផ្សេងៗទៀតរបស់រាជរដ្ឋាភិបាលនៅថ្ងៃអនាគត បង្កឱ្យមានការកកស្ទះចរាចរណ៍ដែលនាំឱ្យរំខានដល់ប្រតិបត្តិការសង្គ្រោះដូចជា រថយន្តសង្គ្រោះបន្ទាន់ រថយន្តពន្លត់អគ្គិភ័យ ការដឹកជញ្ជូនទំនិញ ការធ្វើដំណើររបស់ប្រជាពលរដ្ឋនៅតាមដងផ្លូវ និងបណ្តាលឱ្យមានគ្រោះថ្នាក់ផ្សេងៗជាយថាហេតុ។

*យោងតាមច្បាប់ស្ដីពីផ្លូវថ្នល់ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៤ មាត្រា ៧១ បានចែងថា៖ " ជនណាដែលសាងសង់ដោយខុសច្បាប់នូវសំណង់រឹងមាំ មានលក្ខណៈជាអចិន្ត្រៃយ៍នៅលើដីសម្រាប់អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ត្រូវព្រមានជាលាយលក្ខណ៍អក្សរ និងតម្រូវឱ្យរុះរើចេញនូវសំណង់នោះ។ ក្នុងករណីរឹងទទឹង ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី ១០០ ០០០(មួយសែន)រៀល ទៅ ២០០០ ០០០(ពីរលាន)រៀល "។ មាត្រា ៧៤ បានចែងថា៖ "ជនណាដែល ទន្រ្ទាន ត្រួតត្រា ប្រើប្រាស់ ដោយសាងសង់សំណង់ ឬការរុទាំងឡាយបំពានលើដីរបស់ផ្លូវថ្នល់ ត្រូវផ្ដន្ទាទោស ពិន័យជាប្រាក់ពី ១០០ ០០០(មួយសែន) រៀល ទៅ ១០០០ ០០០ (មួយលាន) រៀល និងតម្រូវឱ្យរុះរើចេញនូវសំណង់ ឬការរុទាំងឡាយនោះ។ ក្នុងករណីរឹងទទឹង ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៦(ប្រាំមួយ) ខែ ទៅ ២(ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០០ ០០០(មួយលាន) រៀល ទៅ ៤០០០ ០០០ (បួនលាន) រៀល "។*

ក្នុងន័យនេះ ដើម្បីធានាបាននូវសោភណភាព សន្តិសុខ សុវត្ថិភាព សណ្ដាប់ធ្នាប់ និងរបៀបរៀបរយនៅតាមដងផ្លូវសាធារណៈ និងជៀសវាងការអនុវត្តវិធានការច្បាប់ **រដ្ឋបាលខេត្តកណ្ដាល** សូមដាក់ចេញវិធានការដូចខាងក្រោម៖

១. ប្រជាពលរដ្ឋ បងប្អូនអាជីវករ ត្រូវបញ្ឈប់ការសាងសង់សំណង់រឹងគ្រប់ប្រភេទនៅលើដីចំណីផ្លូវសាធារណៈ

២. ត្រូវបញ្ឈប់ការតម្លើង ជួសជុល កែច្នៃតូបលក់ដូរ សំយ៉ាប ស្លាកយីហោ ផ័ត្រ ធ្នើរ ខឿន ដាក់លក់លើចិញ្ចើមផ្លូវសាធារណៈ និងត្រូវបញ្ឈប់ការលក់ដូរ ការដាក់តាំងលក់សម្ភារៈនៅលើចំណីផ្លូវសាធារណៈ

៣. ត្រូវរុះរើសំណង់រឹងគ្រប់ប្រភេទ តូបលក់ដូរ សំយ៉ាប ស្លាកយីហោ ផ័ត្រ ធ្នើរ ខឿន ចេញពីដីចំណីផ្លូវសាធារណៈ ដោយស្ម័គ្រចិត្ត

៤. ក្នុងករណីមិនសហការ រដ្ឋបាលក្រុង-ស្រុកទាំង១៣ ត្រូវចុះអនុវត្តវិធានការរដ្ឋបាលរុះរើចេញ ដោយមិនទទួលខុសត្រូវនូវរាល់ការបាត់បង់ ខូចខាតទ្រព្យសម្បត្តិណាមួយឡើយ

៥. ចំពោះផ្ទាំងប៉ាណូ ស្លាកផ្សាយអាជីវកម្មដែលគ្មានច្បាប់អនុញ្ញាត រដ្ឋបាលក្រុង-ស្រុកទាំង១៣ ត្រូវចុះរុះរើចេញ ក្នុងករណីមាននៅក្នុងមូលដ្ឋានត្រូវទទួលខុសត្រូវរៀងៗខ្លួន

៦. ក្នុងករណីរឹងទទឹង អាជ្ញាធរ នឹងអនុវត្តទៅតាមនីតិវិធីច្បាប់ជាធរមាន។

អាស្រ័យហេតុនេះ សូម សាធារណជន បងប្អូនអាជីវករ និងបងប្អូនប្រជាពលរដ្ឋក្នុងខេត្តកណ្ដាល មេត្តាជ្រាប និងចូលរួមសហការអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

**អភិបាល នៃគណៈអភិបាលខេត្តកណ្ដាល**

**គួច ចំរើន**

<u>ចម្លងជូន៖</u>
- ក្រសួងមហាផ្ទៃ
  "ដើម្បីគោរពជូនជ្រាប"
- ស្នងការដ្ឋាននគរបាលខេត្ត
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្ត
- រដ្ឋបាលក្រុង-ស្រុកទាំង១៣
  "ដើម្បីសហការអនុវត្ត"
- មន្ទីរព័ត៌មានខេត្ត
- គ្រប់បណ្ដាញសារព័ត៌មាន
  "ដើម្បីផ្សព្វផ្សាយ"
- ឯកសារ.កាលប្បវត្តិ

អាសយដ្ឋាន ផ្លូវជាតិលេខ២ ភូមិដើមមៀន សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្ដាល ព្រះរាជាណាចក្រកម្ពុជា
Address: NR #2, Doem Mean Village, Doem Mean Commune, Takhmao Town, Kandal Province, Cambodia.